# ឯកសារទស្សនទាននៃ
# សិក្ខាសាលាថ្នាក់ជាតិ
# ស្តីពី ″ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជា
# សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ កម្រិត ២ CFRS – Tier 2″

កាលបរិច្ឆេទ៖ ថ្ងៃ ចន្ទ ទី ១៣ ខែ ធ្នូ ឆ្នាំ ២០២១ ម៉ោង ២.០០ ដល់ ៥.០០ រសៀល

ទីកន្លែង៖ ចូលរួមដោយផ្ទាល់នៅ*មជ្ឈមណ្ឌលដាយកូនៀ* និងចូលរួមពីចម្ងាយតាម Zoom

## ១. សាវតា

ក្របខ័ណ្ឌគតិយុត្តិស្តីពីគណនេយ្យ និងសវនកម្ម និងនិន្នាការបច្ចុប្បន្នភាពនៃការរាតត្បាតនៃជំងឺកូវីដ ១៩ ស្តីពីការធ្វើអនុលោមភាពតាមច្បាប់ ទាក់ទងនឹងប្រតិបត្តិការរបស់ អង្គការសង្គមស៊ីវិលបាន បង្ហាញការវិវត្តគួរឱ្យចាប់អារម្មណ៍ ជាពិសេសលើសមត្ថភាពអនុលោមភាព និងផលជះលើបរិយាកាសអំណោយផលនៅក្នុងប្រទេសកម្ពុជា ។ និយ័តករគណនេយ្យ និងសវនកម្ម (ន.គ.ស) បំពេញមុខងារជាសេនាធិការឱ្យ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការគ្រប់គ្រង និងអភិវឌ្ឍវិស័យ និងវិជ្ជាជីវៈគណនេយ្យ និងសវនកម្មនៅកម្ពុជា តាមរយៈការដាក់ចេញនូវបទប្បញ្ញត្តិ វិធាន និងស្តង់ដា ដោយជំរុញការអនុវត្តច្បាប់ និងស្តង់ដាររបាយការណ៍
ហិរញ្ញវត្ថុ ។

និយ័តករគណនេយ្យ និងសវនកម្មបានរៀបចំរួចរាល់នូវសេចក្តីព្រាងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញកម្រិត ២ និងសេចក្តីព្រាងប្រកាសស្តីពីការដាក់ឱ្យអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុនេះ ដើម្បីឱ្យមានការចូលរួមផ្តល់ធាតុចូលបន្ថែម ។ ស្តង់ដានេះត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីផ្តល់ជាជម្រើសជូនអង្គភាពមិនស្វែងរកប្រាក់ចំណេញក្នុងការបំពេញកាតព្វកិច្ចគណនេយ្យដែលតម្រូវដោយច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ។

ដើម្បីចូលរួមវិភាគទានក្នុងការអភិវឌ្ឍនូវស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជា សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញកម្រិត ២ អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជាបានសម្របសម្រួលកិច្ចពិភាក្សាពិគ្រោះយោបល់កម្រិតបច្ចេកទេសដើម្បីផ្តល់នូវធាតុចូល និង មតិយោបល់ដោយមានកិច្ចសហការពីអង្គការមិនមែនរដ្ឋាភិបាលដើម្បីដាក់ជូន **ន.គ.ស** ពិនិត្យ និងពិចារណា ។

ជាការចូលរួមផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងប្រតិបត្តិការ អង្គការ គ.ស.ក រៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីពីស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ កម្រិត ២ CFRS – Tier 2 ដែលនឹងប្រព្រឹត្តទៅ

DRAFT

នៅ*<u>ថ្ងៃ ចន្ទ ទី ១៣ ខែ ធ្នូ ឆ្នាំ២០២១ ចាប់ពីម៉ោង ២.០០ រសៀលដល់ម៉ោង ៥.០០ រសៀល នៅមជ្ឈមណ្ឌលដាយកូនៀ</u>* ដែលមានអាស័យដ្ឋាននៅអគារលេខ ១៩ ផ្លូវ ៣៣០ សង្កាត់បឹងកេងកង ៣ ក្បែរសារៈមន្ទីរប្រល័យពូជសាសន៍ទួលស្លែង រាជធានីភ្នំពេញ ។

## ២. គោលបំណង

- ដើម្បីលើកកម្ពស់ការយល់ដឹងពីស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ កម្រិត ២ CFRS – Tier 2 (អង្គភាពមិនស្វែងរកប្រាក់ចំណេញ)
- ដើម្បីផ្តល់ឱកាសដល់អង្គការសង្គមស៊ីវិល ក្នុងការលើកឡើងនូវបញ្ហាប្រឈម កង្វល់ និងការលំបាកនានា ទាក់ទងនឹងការអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ កម្រិត ២ CFRS – Tier 2 និងលើកឡើងនូវអនុសាសន៍ និងសំណូមពរនានា ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនោះ និង
- ដើម្បីរៀបចំវិធានមួយចំនួន ចូលរួមលើកកម្ពស់ការយោគយល់គ្នា និងភាពជាដៃគូលើបញ្ហាពាក់ព័ន្ធនានា ដែលជះឥទ្ធិពលដល់អង្គការសង្គមស៊ីវិល ក៏ដូចជានិយ័តករគណនេយ្យ និងសវនកម្ម។

## ៣. អ្នកចូលរួម

សិក្ខាសាលាថ្នាក់ជាតិនេះនឹងធ្វើឡើងដោយមានអ្នកចូលរួមដោយផ្ទាល់ប្រមាណជា ៥០ នាក់ និងចូលរួមពីចម្ងាយតាមរយៈប្រព័ន្ធហ្ស៊ូមប្រមាណជា ១៥០ នាក់ ដែលអញ្ជើញមកពីអង្គការ សមាគម បណ្តាញអង្គការមិនមែនរដ្ឋាភិបាល

## ៤. របៀបវារៈ

| ម៉ោង | មាតិកា | អ្នកសម្របសម្រួល |
|---|---|---|
| ១.៣០ - ២.០០ | ការចុះឈ្មោះអ្នកចូលរួមដោយផ្ទាល់ និង និងគោរពភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា | ក្រុមការងារនៃអង្គការ គ.ស.ក |
| ២.០០ - ២.១០ | ការណែនាំនៃកម្មវិធី និងគោលបំណងសិក្ខាសាលា | ក្រុមការងារនៃអង្គការ គ.ស.ក |
| ២.១០ - ២.៤០ | សុន្ទរកថាស្វាគមន៍ដោយ អ្នកស្រី **ស៊ិន ពុទ្ធារី** នាយិកាប្រតិបត្តិនៃ គ.ស.ក<br><br>សុន្ទរកថាបើកកម្មវិធីឯកឧត្តម **ចៃ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យ និងសវនកម្ម | |
| ២.៤០ - ២.៥៥ | **ថតរូបជុំគ្នា សំរាក និង ពិសារអាហារសំរន់** | ក្រុមការងារនៃអង្គការ គ.ស.ក |
| ២.៥៥ - ៣.៥៥ | **បទបង្ហាញស្តីពីៈ**<br>ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ កម្រិត ២ CFRS – Tier 2 | ក្រុមការងារនៃនិយ័តករគណនេយ្យ និងសវនកម្ម |

DRAFT

| | | |
|---|---|---|
| ៣.៤៥ - ៤.៤៥ | **វេទិកាសំនួរ និង ចម្លើយ** | |
| ០៤.៤៥ - ០៥.០០ | **សេចក្តីសង្ខេប និង មតិបិទកម្មវិធី** | សមាជិកក្រុមការងារអង្គការសង្គមស៊ីវិល |

DRAFT